# តារាងដួងជតា១២រាសី



## ពិធីរាប់ដួងជតា១២រាសី

+បើចង់មើលពីដួងជរា១២រាសី ថ្ងៃកំណើតរបស់យើងឱ្យដឹងថាល្អ អាក្រក់យ៉ាងណានោះ បើប្រុសលោកឱ្យចាប់ពីចេតិយ៏រៀងទៅឆត្រប្រាក់ បើស្រីឱ្យរាប់ពីចេតិយ៏រៀងទៅនាគរាជ រហូតទៅដល់ថ្ងៃដែលយើងកើត ។

បើចង់មើលពីខែ ឱ្យរាប់ពីមិគសិរត្រង់ចេតិយ៏ ។

បើចង់មើលពីថ្ងៃកំណើត ឱ្យរាប់ពីអាទិត្យ ត្រង់ចេតិយ៏ បើរាប់ទៅត្រូវត្រង់លើរូបណា នឹងមានទំនាយដូចខាងក្រោមនេះ :

១-បើត្រូវត្រង់ចេតិយ៏ ទំនាយថា ជាមនុស្សដែលចូលចិត្តប្រព្រឹត្តនូវអំពើទៀងត្រង់ មានសេចក្តី ព្យាយាម និងមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ជាមនុស្សដែលមិនត្រេកត្រអាល លោភលន់និងបុណ្យសក្តិ មានចរិយានឹងធ្ងន់ សុភាពរាបសារ ចេះគោរពប្រតិបត្តិចាស់ទុំ ព្រឹទ្ធាចារ្យ លាភសក្ការៈហូរចូលជារឿយៗ។

២-បើត្រូវត្រង់ឆ័ត្រនាស និងឆ័ត្រប្រាក់ ទំនាយថា នឹងបានលាភយសសក្តិគួរជាទីពេញចិត្ត អ្នកផងស្រឡាញ់រាប់អាន សត្រូវប៉ុនប៉ងប្រទូស្តរ៉ាយមិនបាន ជាមនុស្សដែលមានប្រាជ្ញាស្មារតីខ្ពង់ខ្ពស់ មានវេហាស៍ ទៀងត្រង់ និងបានជាធំ លើសគេទាំងពួង ។

៣-បើត្រូវត្រង់មនុស្សកំបុតក្បាល ទំនាយថាអាក្រក់ណាស់ នឹងកើតមានរឿងទុក្ខសោកដល់ខ្លួន ជាមនុស្សអភ័ព្វ ស្វែងរកលាភពុំសូវបាន មានកើតក្ដីក្ដៅក្រហាយក្នុងចិត្តជារឿយៗ ។

៤-បើត្រូវត្រង់ផ្ទះហ្លួង ទំនាយថាល្អបង្គួរ នឹងបានលាភផលផ្សេងៗ បើមានភ័យន្តរាយអ្វីនឹងមាន គេជួយ ។

៥-បើត្រូវត្រង់ប្រាសាទមាស ទំនាយថាល្អប្រសើរណាស់ បានចៅហ្វាយនាយផ្គុំផ្គង់ផ្ដើម និងត្រូវបានបុណ្យសក្តិខ្ពង់ខ្ពស់ គួរជាទីរាប់អាននៃអ្នកផងទាំងពួង មានគេគោរពស្រឡាញ់កោតខ្លាចច្រើន សត្រូវប៉ុនប៉ងព្យាបាទមិនបាន ។

៦-បើត្រូវត្រង់រាហ៊ូ ទំនាយថានឹងមានកើតក្ដីក្ដៅក្រហាយក្នុងចិត្តច្រើន មានគំនុំគុំគួននៅក្នុង ខ្លួន ។

៧-បើត្រូវត្រង់ទេវតាចរ ទំនាយថាជាមនុស្សងប់នឹងល្បែង មានទីលំនៅមិនប្រាកដប្រជា ជាមនុស្សដែលមានចិត្តមិនទៀង លាភសក្ការៈច្រើនបានមកពីទីឆ្ងាយ ។

៨-បើត្រូវត្រង់ពិម្ពាសារ ទំនាយថានឹងកើតមានរឿងរ៉ាវ ឈ្លោះប្រកែកពាក្យសម្ដីនឹងគ្នា ចូរប្រយ័ត្នកុំលលេងនឹងស្រី ឬដើរយប់ព្រលប់ នាំឱ្យមានទុក្ខទោសអន្តរាយដល់ខ្លួន ។

៩-បើត្រូវត្រង់ពេទ្យហ្ម ទំនាយថានឹងត្រូវបានអ្នកធំនាំលាភយសសក្តិមកឱ្យ ។

១០-បើត្រូវត្រង់មេមត់ ទំនាយថាជាមនុស្សមានបញ្ញាច្រើន តែច្រើននិយាយត្រឡប់ត្រឡិន លាភសក្ការៈច្រើនបានដោយសារស្រីនាំយកមកឱ្យ ។

១១-បើត្រូវត្រង់នាគរាជ ទំនាយថាជាមនុស្សដែលមានចិត្តរោលរាលក្ដៅក្រហាយច្រើន ជាមនុស្សសន្សំរឿង សម្ដីចរចាគំរោះគំរើយ មានមនុស្សប៉ុនប៉ងព្យាបាទច្រើនណាស់ ជាមនុស្សដែលមានចិត្តកំណាញ់ឫស្យា  មិនខ្មាសអៀនឡើយ ។